# ការណែនាំសម្រាប់ឪពុកម្តាយ ឬអ្នកថែទាំទារក អាយុ 0 - 30 ថ្ងៃ

## តើខ្ញុំគួរទូរស័ព្ទទៅលេខ 911 នៅពេលណា?



## តើខ្ញុំគួរទាក់ទងទៅអ្នកថែទាំសុខភាពទារករបស់ខ្ញុំនៅពេលណា?

អ្នកគួរទាក់ទងទៅអ្នកផ្តល់សេវាថែទាំសុខភាពទារករបស់អ្នក ប្រសិនបើពួកគេមានរោគសញ្ញា COVID-19 ដូចខាងក្រោម៖

- មានគ្រុនក្តៅចាប់ពី 100° F (37.8°C) ឡើងទៅ
- គេងមិនងាយភ្ញាក់
- ខ្សោយនៅពេលយំ ឬបៅ
- ម៉ូរម៉ៅ ឬយំច្រើន
- ពិបាកដកដង្ហើម ដែលមើលទៅដូចជា៖
  - o ដកដង្ហើមញាប់ជាងមុន ដូចជា លើសពី 60 ដងក្នុងមួយនាទីរៀងរាល់[1]
  - o ពោះផតចូលខុសពីធម្មតានៅពេលដកដង្ហើម
  - o ស្បែករឹតឆ្អឹងជំនី និងឆ្អឹងក នៅពេលដកដង្ហើមចេញចូល
  - o រន្ធច្រមុះរីកធំ
  - o ក្បាលងើបចុះឡើងនៅពេលដកដង្ហើមចេញចូល
  - o ដកដង្ហើមលាន់សំឡេងខ្លាំង ដូចជា ដកដង្ហើមតឹង ឬឮសំឡេងដូចថ្ងូរ។
  - o រុញដោះម្តាយ ឬដបទឹកដោះគោចេញដើម្បីដកដង្ហើម
- ស្បែកមានការប្រែប្រួល ដូចជា៖
  - o បែកញើស ឬស្បែកឡើងស្អិត
  - o ស្បែកមានពណ៌ចម្រុះ ស្លេកខ្លាំង ឬពណ៌ខៀវ
- ហៀរសំបោរ
- ក្អក
- ក្អួត
- រាករូស
- មិនចង់បៅ
- រោគសញ្ញាខ្សោះជាតិទឹក ដូចជា៖
  - o ស្ងួតបបូរមាត់ និងមាត់
  - o អត់នោមច្រើន (តិចជាង 4 ទៅ 6 ដង ក្នុងរយៈពេល 24 ម៉ោង)
  - o ភ្នែកស្រអាប់

**បញ្ជីនេះមិនមានរោគសញ្ញាដែលអាចកើតឡើងទាំងអស់ឡើយ។ សម្រាប់រោគសញ្ញាធ្ងន់ធ្ងរផ្សេងទៀត សូមទាក់ទងអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់អ្នក។**

## តើខ្ញុំគួរទូរស័ព្ទទៅ 911 ដើម្បីរាយការណ៍អំពីទារករបស់ខ្ញុំនៅពេលណា?

ទារករបស់អ្នកត្រូវការជំនួយវេជ្ជសាស្ត្រភ្លាមៗ ប្រសិនបើពួកគេមានរោគសញ្ញាណាមួយដូចខាងក្រោម៖

- ពួកគេឈប់ដកដង្ហើមរយៈពេល 15 វិនាទី ឬលើសពីនេះ។
- ពិបាកដកដង្ហើមធ្ងន់ធ្ងរ ដូចជា ប្រឹងស្រូបខ្យល់។
- ស្បែកឡើងពណ៌ខៀវ ជាពិសេសនៅជុំវិញបបូរមាត់ ក្រចកដៃ និងអញ្ចាញធ្មេញ។ ពណ៌នេះប្រហែលជាមើលមិនឃើញនៅលើស្បែកដែលមានសម្បុរខ្មៅទេ ដូច្នេះត្រូវយកចិត្តទុកដាក់ចំពោះការដកដង្ហើម និងឥរិយាបថរបស់កូនអ្នក។
- អ្នកមិនអាចដាស់កូនរបស់អ្នក។
- កូនរបស់អ្នកមានអាការៈប្រកាច់។

ប្រសិនបើអ្នកទូរស័ព្ទទៅលេខ 911 សូមប្រាប់អ្នកលើកទូរស័ព្ទថា អ្នកកំពុងស្វែងរកសេវាថែទាំទារក ឬកុមារដែល មាន ឬអាចមានជំងឺ COVID–19។

[1] វិធីរាប់ចំនួនដង្ហើមរបស់កូនអ្នក៖ នៅពេលទារក / កូនតូចរបស់អ្នកកំពុងគេង ចូររាប់ចំនួនដងដែលពោះរបស់ពួកគេពើងឡើង និងផតចូល ក្នុងរយៈពេល 30 វិនាទី។ ចំនួនពើងឡើង និងផតចូលមួយដង គឺស្មើនឹងនឹងមួយដង្ហើម។ ចូរគុណចំនួននោះនឹងពីរដើម្បីរកចំនួនដង្ហើមក្នុងមួយនាទី។ នៅពេលកូនរបស់អ្នកមានបញ្ហាដង្ហើម ពួកគេអាចនឹងដកដង្ហើមញាប់ជាងមុន។


**ALAMEDA COUNTY HEALTH CARE SERVICES AGENCY**
**PUBLIC HEALTH DEPARTMENT**

Colleen Chawla – Agency Director
Kimi Watkins-Tartt – Director
Nicholas Moss, MD – Health Officer

**Contact**

Public Health Department:
(510) 267-8000 Main Line

COVID-19 Information:
(510) 268-2101

www.acphd.org